ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧៤៦ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០៣

ប្រកាស
ស្តីពី
ការតែងតាំងគ្រូមប្រឹក្សាភិបាល
ប្រចាំ
វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៨ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទិ០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស, សវនកម្មគណនេយ្យសហគ្រាស និង វិជ្ជាជីវៈគណនេយ្យ,
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ/បក ចុះថ្ងៃទិ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,
- បានឃើញអនុក្រឹត្យលេខ ១៨/អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា-វ.គ.ស.ក.
- បានឃើញការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

ប្រការ១ : តែងតាំង :-

| | | | | |
|---|---|---|---|---|
| ១.- | លោក | កាក់ គី | តំណាងក្រុមហ៊ុន Morison Kak & Associés | ជា ប្រធាន |
| ២.- | អ្នកស្រី | ជុង ពៅនី | តំណាងក្រុមហ៊ុន FIDES | ជា អនុប្រធាន |
| ៣.- | លោក | មាស សក្តិសម | តំណាងក្រុមហ៊ុន Morison Kak & Associés | ជា ហិរញ្ញិក |
| ៤.- | លោក | គួយ លឹម | តំណាងក្រុមហ៊ុន PriceWaterHouseCoopers | ជា សមាជិក |
| ៥.- | លោក | ទៃ ថឿយ | តំណាងក្រុមហ៊ុន KPMG | ជា សមាជិក |

ជាក្រុមប្រឹក្សាភិបាលក្នុងអាណត្តិទី១ របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា-វ.គ.ស.ក ។

ប្រការ២ : អាណត្តិទី១ ដែលមានរយៈពេលបួន "៤" ឆ្នាំ ត្រូវបានគិតចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៣ ដល់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៧ ។

ប្រការ៣ : អគ្គលេខាធិការ, នាយកខុទ្ទកាល័យ, ប្រធាននាយកដ្ឋានបុគ្គលិក, ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ, អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីជន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ,តាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

*កន្លែងទទួល* :-
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣
- ឯកសារ/កាលប្បវត្តិ